**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ធានរ៉ាប់រងត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ :...១១៤...បទ.គល

ថ្ងៃចន្ទ ៧រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ
## ជួសជុល ផ្លាស់ប្តូរឧបករណ៍បច្ចេកទេស និងបង្កើត Access Note ដែលមានលក្ខណៈ Redundancy បន្ថែមចំនួន ០៦ក្រសួង ស្ថាប័នក្នុងរាជធានីភ្នំពេញ និងបំពាក់ប្រព័ន្ធ Software សម្រាប់គ្រប់គ្រងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិនៅអគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមជូនដំណឹងចំពោះក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកតបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការជួសជុល ផ្លាស់ប្តូរឧបករណ៍បច្ចេកទេស និងបង្កើត Access Note ដែលមានលក្ខណៈ Redundancy បន្ថែមចំនួន ០៦ក្រសួង ស្ថាប័នក្នុងរាជធានីភ្នំពេញ និងបំពាក់ប្រព័ន្ធ Software សម្រាប់គ្រប់គ្រងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិនៅអគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានអាសយដ្ឋានអគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី...២០....ខែមេសា....ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ( ទូរសព្ទទាក់ទងលេខ ០២៣ ៤២៧ ៥០៧ )។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅវេលាម៉ោង១៥:៣០រសៀល ថ្ងៃទី...២៥...ខែឧសភា...ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៥:៣០...រសៀល ថ្ងៃទី២៥...ខែឧសភា...ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានបន្ថែមដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**សារ៉ាក់ ខាន់**

ចម្លងជូន :
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកសារ កាលប្បវត្តិ